**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ** ១៣៤ សរ.ស.ណ

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សូមគោរពជូន**

**-សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**-ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ ÷** ស្តីពីវិធានការដោះស្រាយក្នុងការអនុវត្តប្រមូលពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ចំពោះអចលនទ្រព្យដែលបានចុះបញ្ជី និងពុំបានចុះបញ្ជី ។

**យោង ÷** - លិខិតលេខ ១១៧ សហវ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនសម្តេចក្រឡាហោម ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាបថា រាជរដ្ឋាភិបាលបានយល់ព្រមទៅលើសំណើសុំការសម្រេចជាគោលការណ៍ ចំពោះករណីសំណើសុំវិធានការដោះស្រាយ ក្នុងការអនុវត្តប្រមូលពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យដែលបានចុះបញ្ជីរួច (មានបណ្ណកម្មសិទ្ធិ) និងពុំបានចុះបញ្ជី (គ្មានបណ្ណកម្មសិទ្ធិ)។

ក្នុងន័យពង្រឹងការគ្រប់គ្រងប្រមូលពន្ធប្រភេទនេះប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងអស់សក្តានុពលព្រមទាំងជៀសវាងនូវបាតុភាពអសកម្មជាយថាហេតុណាមួយ រាជរដ្ឋាភិបាលកម្ពុជាបានយល់ព្រមទៅលើសំណើសុំវិធានការជាដំណោះស្រាយក្នុងការអនុវត្តប្រមូលពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យចំពោះអចលនទ្រព្យដែលបានចុះបញ្ជីរួច(មានបណ្ណកម្មសិទ្ធិ)និងពុំបានចុះបញ្ជី(គ្មានបណ្ណកម្មសិទ្ធិ) ដូចខាងក្រោម ៖

១. អចលនទ្រព្យដែលបានចុះបញ្ជីរួច (មានបណ្ណកម្មសិទ្ធិ)

- ចំពោះការកកស្ទះបណ្ណកម្មសិទ្ធិ អនុញ្ញាតឱ្យបង់ពន្ធប្រថាប់ត្រាតែមួយលើកចុងក្រោយ ទោះជាអចលនទ្រព្យនោះមានសារតារផ្ទេរបន្តដៃគ្នាជាច្រើនដងក៏ដោយ និងទុករយៈពេល ០៦ខែ ដើម្បីឱ្យរដ្ឋបាលសុរិយោដីធ្វើការដោះស្រាយបញ្ចេញបណ្ណកម្មសិទ្ធិដែលបានកកស្ទះនោះ។ ទន្ទឹមនឹងនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវផ្តល់របាយការណ៍លម្អិតនូវព័ត៌មានអចលនទ្រព្យដែលកកស្ទះមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជាមូលដ្ឋានក្នុងការកត់ត្រាទិន្នន័យសម្រាប់ការប្រមូលពន្ធប្រថាប់ត្រា នៅពេលក្រោយៗទៀត និងសម្រាប់ជាទិន្នន័យក្នុងការប្រមូលពន្ធលើអចលនទ្រព្យ
- អាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិ (ថ្នាក់ឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ) ត្រូវបញ្ឈប់ការផ្ទេរកម្មសិទ្ធិដែល មិនបានបង់ពន្ធប្រថាប់ត្រា ឬបង់ពន្ធប្រថាប់ត្រាក្រៅប្រព័ន្ធ ហើយជំរុញ និងបញ្ជូនរាល់ករណីស្នើសុំផ្ទេរកម្មសិទ្ធិទាំងនោះឱ្យមកបង់ពន្ធប្រថាប់ត្រានៅរដ្ឋបាលសារពើពន្ធ តាមការសម្រេចដ៏ខ្ពង់

Collection by VCAT Professional Consultant

ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ លើលិខិតលេខ ១៧៦ សហវ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២. អចលនទ្រព្យពុំបានចុះបញ្ជី (គ្មានបណ្ណកម្មសិទ្ធិ)

- ចំពោះការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលពុំបានចុះបញ្ជី (គ្មានបណ្ណកម្មសិទ្ធិ) ដែលបានផ្ទេរនៅថ្នាក់ឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ អនុញ្ញាតឱ្យបង់ពន្ធប្រថាប់ត្រាតែមួយលើកចុងក្រោយ ទោះជាអចលនទ្រព្យនោះមានសារតារផ្ទេរបន្តដៃគ្នាជាច្រើនដងក៏ដោយ។ ជាមួយនេះ ត្រូវជំរុញឱ្យអ្នកកាន់កាប់អចលនទ្រព្យរួសរាន់ទៅចុះបញ្ជីនៅរដ្ឋបាលសុរិយោដី ដោយភ្ជាប់នូវបង្កាន់ដៃបង់ពន្ធប្រថាប់ត្រានោះ
- អាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិ (ថ្នាក់ឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ) ត្រូវបញ្ឈប់ការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនបានបង់ពន្ធប្រថាប់ត្រា តាមការសម្រេចដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ លើលិខិតលេខ ១៧៦ សហវ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសម្តេចក្រឡាហោម ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាប និងចាត់ចែងតាមការគួរ។

ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
រដ្ឋលេខាធិការ

Thong

បណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី

**ចម្លងជូន៖**

- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់*
- *ឯកសារ-កាលប្បវត្តិ*

Collection by VCAT Professional Consultant